**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**គណៈកម្មាធិការលទ្ធកម្ម**

លេខៈ ១៩៧/ស.ស.ណ/២០១៩

ថ្ងៃ ច័ន្ទ ១៤រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៩

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការអញ្ជើញចូលរួមដេញថ្លៃ**

**ផ្គត់ផ្គង់សម្ភារៈគ្រឿងបន្លាស់បញ្ជូនសារ សម្រាប់ប្រើប្រាស់ឆ្នាំ២០១៩**

ក្រសួងការពារជាតិ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក(គិតទាំងសហគ្រាសឯកត្តបុគ្គល) និងក្រុមហ៊ុនបរទេសទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសមត្ថភាពគ្រប់គ្រាន់និងមានបទពិសោធន៍ពិតប្រាកដ អោយបានជ្រាបថា៖

ក្រសួងការពារជាតិ នឹងដាក់អោយដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់សម្ភារៈគ្រឿងបន្លាស់បញ្ជូនសារ សម្រាប់ប្រើប្រាស់ឆ្នាំ២០១៩ ។

អង្គភាពលទ្ធកម្ម ក.ព.ជ
បានពិនិត្យត្រឹមត្រូវ

ក្រសួងការពារជាតិបានរៀបចំឯកសារសម្រាប់ជូនក្រុមហ៊ុនយកទៅបំពេញ ដើម្បីចូលរួមដេញថ្លៃនិងមានដាក់លក់នៅអង្គភាពលទ្ធកម្ម អាស័យដ្ឋានក្នុងទីស្តីការក្រសួងការពារជាតិ នៅជ្រុងខាងលិចឈៀងខាងត្បូង ចាប់ពីថ្ងៃទី ០១ ខែ សីហា ២០១៩ តទៅ នៅរាល់ម៉ោងធ្វើការ ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់អោយអង្គភាពលទ្ធកម្មក្រសួងការពារជាតិ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៩ វេលាម៉ោង១៥:៣០ ។ ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅជាបន្តបន្ទាប់នៅទីស្តីការក្រសួងការពារជាតិតាមអាស័យដ្ឋានខាងលើ វេលាម៉ោង១៥:៣០ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៩ ចំពោះមុខគណៈកម្មាធិការ និងប្រធានឬអនុប្រធានក្រុមហ៊ុន ដែលបានចូលរួមដេញថ្លៃ ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មក្រសួងការពារជាតិ ដើម្បីទិញឯកសារ និងសាកសួរព័ត៌មាន ដែលទាក់ទងដល់ការដេញថ្លៃនេះ ។

**ជ-គណៈកម្មាធិការលទ្ធកម្ម ក្រសួងការពារជាតិ**

**អនុប្រធាន**

**នាយឧត្តមសេនីយ៍.ស៊ឹ_សំណាង**

**សូមជាក់ចាប**

ទូរស័ព្ទលេខៈ ០៩៧ ៥៥៦៦ ៥៥៩ (អង្គភាពលទ្ធកម្ម)

០៩៧ ៩៧៩៧ ១១១ (បញ្ជូនសារ)

**កន្លែងចម្លង**

- អង្គភាព ប្រឆាំងអំពើពុករលួយ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- ឯកសារ-កាលប្បវត្តិ